# *តើអ្នកត្រូវការជំនាញថ្មីដើម្បីទទួលបានការងារឬទេ?*

## សូមដាក់ពាក្យចូលរួមក្នុងកម្មវិធីឱកាសទទួលការបណ្តុះបណ្តាល (TOP)



កម្មវិធីឱកាសទទួលការបណ្តុះបណ្តាល (ដោយខ្លីបំព្រួញ TOP) អនុញ្ញាតអ្នកអោយប្រមូលយកបាននូវអត្ថប្រយោជន៍នៃភាពអត់មានការងារធ្វើក្នុងខណៈអ្នកចូលរួមរៀនសូត្រក្នុងការបណ្តុះបណ្តាល ពេញម៉ោងដើម្បីជំនាញការងារថ្មី។

ប្រសិនបើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អ្នកអាចៈ

- ប្រមូលយកនូវអត្ថប្រយោជន៍នៃការអត់មានការងារធ្វើ, ***ដោយមិនបាច់*** ត្រូវស្វែងរកការងារ ហើយ
- ពន្យារពេលអត្ថប្រយោជន៍នៃភាពអត់ការងារធ្វើរបស់អ្នករហូតដល់ 26 សប្តាហ៍

### តើនរណាខ្លះអាចនៅក្នុងកម្មវិធី TOP បាន?

អ្នកអាចនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ប្រសិនបើៈ

- អ្នកលែងធ្វើការតទៅទៀតហើយអោយអតីតនយោជករបស់អ្នក
- អ្នកបានដាក់អំណះអំណាងនិងមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍នៃភាពអត់ការងារធ្វើ។
- វានឹងពិបាកសម្រាប់រូបអ្នកក្នុងការទទួលបានការងារថ្មី លុះត្រាតែអ្នកទទួលបានជំនាញថ្មីសិន។
- អ្នកមានជំនាញដើម្បីបំពេញបញ្ចប់អោយចប់ចុងចប់ដើមនិងទទួលបានអត្ថប្រយោជន៍ពីការបណ្តុះ បណ្តាលដែលត្រូវបានអនុម័តយល់ព្រម។
- កម្មវិធីបណ្តុះបណ្តាលរបស់អ្នកគឺពេញម៉ោងហើយត្រូវបាន អនុម័តយល់ព្រមដោយផ្នែក TOP។

### តើមានកាលកំណត់សម្រាប់ដាក់ពាក្យចូលរួមទេ?

អ្នកត្រូវតែដាក់ពាក្យចូលរួមក្នុងកំឡុងពេល20 សប្តាហ៍ដំបូងដែលអ្នកទទួលបាននូវអត្ថប្រយោជន៍នៃភាពអត់ការងារធ្វើ។

**ដំបូន្មានគន្លឹះ:** ដាក់ពាក្យសុំចូលរួមកម្មវិធី TOP អោយបានឆាប់តាមដែលអ្នកបានដឹងថាអ្នកមានសិទ្ធិសក្តិសមសម្រាប់អត្ថប្រយោជន៍នៃភាពអត់ការងារធ្វើ **និង** មានមុខវិជ្ជាបណ្តុះបណ្តាល។

### តើការបណ្តុះបណ្តាលប្រភេទណាដែលខ្ញុំអាចជ្រើសរើសបាន?

ជ្រើសរើសកម្មវិធីបណ្តុះបណ្តាលដែលនឹងផ្តល់ដល់អ្នកនូវ ជំនាញការងារដែលកំពុងមានតម្រូវការ។

អ្នកអាចជ្រើសរើសការបណ្តុះបណ្តាលសម្រាប់ការងារដែលកំពុងមាន តម្រូវការនៅទីកន្លែងដែលអ្នករស់នៅពេលនេះ ឬនៅកន្លែងមួយផ្សេងទៀតដែលអ្នកនឹងធ្វើដំណើរទៅធ្វើការឬរើទៅកាន់។

សិក្សាស្វែងយល់បន្ថែមទៀតអំពីទីផ្សារការងារនិងការងារមួយណាកំពុងមានតម្រូវការនៅគេហទំព័រ: **www.mass.gov/lmi**.

### តើការបណ្តុះបណ្តាលមិនគិតថ្លៃទេមែនទេ ?

មិនមែនទេ។ អ្នកត្រូវតែបង់ប្រាក់សម្រាប់ការបណ្តុះបណ្តាលឬ ស្វែងរកអាហារូបករណ៍ ឬថវិការទ្រទ្រង់ដែលអាចជួយអ្នកអោយបង់ប្រាក់បាន។

នេះគឺប្រភពព័ត៌មានស្តីអំពីជំនួយហិរញ្ញវត្ថុខ្លះៗ:

- **មណ្ឌលអាជីពការងារតែមួយដំណាក់ ម៉ាស្សាឈូសេត:** សូមទៅកាន់មជ្ឈមណ្ឌលប្រចាំតំបន់របស់អ្នក។ សូមស្នើរសុំអ្នកឯកទេសខាងការងារអោយជួយអ្នកស្វែងរកថវិការទ្រទ្រង់ឬប្រាក់កម្ចី។
- **ជំនួយហិរញ្ញវត្ថុសហព័ន្ធ:** ដើម្បីស្វែងយល់ថាតើអ្នកមានសុពលភាពសម្រាប់ជំនួយផ្នែកហិរញ្ញវត្ថុដែរឬទេ រួមមានជំនួយថវិការ Pell ក្នុងចំនួនរហូតដល់ $ 5350 និងថវិការទ្រទ្រង់និងប្រាក់កម្ចីដទៃទៀត សូមអ្នកបំពេញ **ពាក្យសុំដោយឥតគិតថ្លៃសម្រាប់ជំនួយនិស្សិតសហព័ន្ធ (FAFSA)។**
- ប្រសិនបើអ្នកមានសញ្ញាប័ត្រមហាវិទ្យាល័យរយៈពេលបួនឆ្នាំហើយនោះអ្នកនឹងមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ថវិការទ្រទ្រង់ Pell ឡើយ ប៉ុន្តែអ្នកអាចនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ជំនួយប្រភេទដទៃទៀត។
- សូមចូលទៅកាន់គេហទំព័រ **www.opportunity.gov** សម្រាប់ព័ត៌មានអំពីជំនួយផ្នែកហិរញ្ញវត្ថុនិងវិធានដើម្បីជួយអ្នកអោយរុករកឃើញនូវអាជីពការងារនិងជម្រើសដ៏ច្រើន។

### តើខ្ញុំដឹងដោយរបៀបណាថាតើកម្មវិធីរបស់ខ្ញុំត្រូវបានអនុម័តយល់ព្រម?

អ្នកអាចស្វែងយល់ដឹងថាការបណ្តុះបណ្តាលអ្វីត្រូវបាន អនុម័តយល់ព្រមដោយផ្នែកផ្តល់ជំនួយក្នុងភាពអត់ការងារធ្វើដោយ:

- ទូរស័ព្ទទៅកាន់ផ្នែកកម្មវិធីឱកាសទទួលការបណ្តុះបណ្តាលតាមរយៈ លេខ 617-626-5521, ឬ
- ទៅកាន់មជ្ឈមណ្ឌលអាជីពការងារតែមួយដំណាក់ម៉ាស្សាឈូសេត, ឬ
- ធ្វើការស្វែងរកនៅក្នុងគេហទំព័រ **www. mass.gov/jobquest**

កម្មវិធីដែលអ្នកជ្រើសរើសត្រូវតែជាកម្មវិធីបណ្តុះបណ្តាលជំនាញលក្ខណៈសម្រុកពេញម៉ោង ផ្នែកវិជ្ជាជីវៈ បច្ចេកទេសឬមូលដ្ឋានដែលអ្នកអាចបញ្ចប់នៅក្នុងរយៈពេល 2 ឆ្នាំ។ ដូចគ្នានេះដែរកម្មវិធីគួរតែ:

- ផ្តល់ដល់អ្នកនូវឱកាសដាក់ចូលក្នុងការងារសម្រាប់វិជ្ជាជីវៈជាក់លាក់មួយមុនពេលការបណ្តុះបណ្តាលចប់។
- មានភាពជោគជ័យដែលសអោយឃើញច្បាស់នៅក្នុងការរកការងារអោយអ្នកទទួលការបណ្តុះ បណ្តាលស្រដៀងគ្នាបានធ្វើ និង
- ផ្តល់នូវភស្តុតាងដែលការបណ្តុះបណ្តាលនឹងជួយអ្នកអោយទទួលបាននូវការងារថ្មី។

| ប្រភេទនៃកម្មវិធី | លក្ខខណ្ឌតម្រូវការអប្បបរមា |
|---|---|
| ការបណ្តុះបណ្តាលវិជ្ជាជីវៈ/ផ្នែកឧស្សាហកម្ម | ក្នុងមួយសប្តាហ៍មានម៉ោងសិក្សាដោយមានការអនុរក្សឃ្លាំមើលចំនួន 20 ម៉ោង សូមមើលក្នុងគេហទំព័រ: **www.mass.gov/dpl** |
| ការបណ្តុះបណ្តាលនៅសាលារៀន-មហាវិទ្យាល័យ | មាន 12 ក្រេឌិតក្នុងមួយឆមាសនៅសាលារៀនឬនៅមហាវិទ្យាល័យដែលត្រូវបានផ្តល់អជ្ញាប័ណ្ណដោយនាយកដ្ឋានអប់រំរដ្ឋ សូមមើលគេហទំព័រ: **www.mass.edu** |
| ការបណ្តុះបណ្តាលបែបសិក្សាពីចម្ងាយ | មាន 12 ក្រេឌីតក្នុងមួយឆមាស ឬ 20 ម៉ោងក្នុងមួយសប្តាហ៍ – ***មិនអាចជាការសិក្សាដែលប្រព្រឹត្តតាមដំណើរឆ្លើយតបរបស់អ្នករៀនឡើយ ; ត្រូវតែគោរពតាមកម្មវិធីដែលបានផ្តួចផ្តើមកំណត់យក។*** |
| កម្មសិក្សារយៈពេលវែងនិងរយៈពេលខ្លី | មានម៉ោងសិក្សាចំនួន 20ម៉ោងក្នុងមួយសប្តាហ៍ ប្រសិនបើវាជាផ្នែកនៃកម្មវិធីដែលបានផ្តួចផ្តើមកំណត់យក។ |
| | សូមទូរស័ព្ទមកផ្នែក TOP ដើម្បីមើលថាតើកម្មវិធីរបស់អ្នកមានលក្ខណៈគ្រប់គ្រាន់ឬទេ ប្រសិនបើវា:<br>• មុខវិជ្ជាសិក្សាមួយផ្នែក កម្មសិក្សារយៈពេលវែងឬការអនុវត្តន៍មួយផ្នែក<br>• កម្មវិធីថ្នាក់បរិញ្ញាបត្រ ឬថ្នាក់ក្រោយបរិញ្ញាបត្រ |

## ចុះបើសិនខ្ញុំត្រូវការការបណ្តុះបណ្តាលជំនាញមូលដ្ឋានជាមុនសិនវិញ តើយ៉ាងម៉េចដែរ?

អ្នកអាចនឹងត្រូវការជំនាញមូលដ្ឋានមុនពេលអ្នកអាចចាប់ផ្តើមធ្វើកម្មវិធីបណ្តុះបណ្តាល។ ឧទាហរណ៍ អ្នកអាចនឹងត្រូវ:

- កែលម្អរអោយកាន់តែប្រសើរនូវជំនាញអំណាន សំណេរ ឬគណិតវិទ្យារបស់អ្នក
- រៀនភាសាអង់គ្លេសប្រសិនបើវាមិនមែនជាភាសាបឋមរបស់អ្នកទេ ឬ
- ត្រៀមរៀបចំខ្លួនសម្រាប់ការប្រលងពិនិត្យសមត្ថភាពសមមូលនឹងថ្នាក់វិទ្យាល័យប្រសិនបើអ្នកមិនបានបញ្ចប់ការសិក្សាចេញពីថ្នាក់វិទ្យាល័យទេនោះ។

ប្រសិនបើអ្នកត្រូវការជំនាញណាមួយនៃជំនាញមូលដ្ឋានទាំងនេះ ផែនការវិជ្ជាជីវៈរបស់អ្នកនឹងបូកបញ្ចូលនូវថ្នាក់សិក្សាពីមុខវិជ្ជាមួយឬច្រើននៃមុខវិជ្ជា ទាំងនេះ:

- ភាសាអង់គ្លេសជាភាសាទីពីរ
- ការអប់រំមូលដ្ឋានសម្រាប់មនុស្សពេញវ័យ(ABE), ឬ
- សញ្ញាប័ត្រសមមូលចំណេះទូទៅ(GED)

កម្មវិធី TOP អនុញ្ញាតអ្នកអះអាងទាមទារដែលត្រូវការជំនាញមូលដ្ឋាននូវរយៈពេលចំនួន 3 ឆ្នាំដើម្បីបំពេញបញ្ចប់កម្មវិធីរបស់ពួកគេ។ ប្រការនោះនឹងផ្តល់ដល់អ្នកនូវពេលវេលាក្រៅថែមដើម្បីសិក្សាជំនាញមូលដ្ឋានដែលអ្នកត្រូវការព្រមពេលដំណាលគ្នានឹងការបណ្តុះបណ្តាលវិជ្ជាជីវៈឬបច្ចេកទេស។

***ចំណុចសំខាន់!*** រយៈពេលមានសិទ្ធិរបស់អ្នកសម្រាប់អត្ថប្រយោជន៍មិនប្រែប្រួលទេ។

## តើខ្ញុំដាក់ពាក្យចូលរួមយ៉ាងដូចម្តេច?

ដើម្បីដាក់ពាក្យចូលរួមក្នុងកម្មវិធី TOP និងពន្យាររយៈពេលអត្ថប្រយោជន៍ភាពអត់ការងារធ្វើរបស់អ្នក សូមធ្វើតាមជំហានទាំងនេះ:

1. ស្វែងរកអោយបាននូវកម្មវិធីបណ្តុះបណ្តាលដែលត្រូវបានអ នុម័តយល់ព្រមដែលនឹងរៀបចំខ្លួនអ្នកសម្រាប់ទីផ្សារការងារ។ វិធីប្រសើរបំផុតដើម្បីធ្វើរឿងនេះគឺ:

- ទៅកាន់មជ្ឈមណ្ឌលអាជីពការងារតែមួយដំណាក់ណាមួយនៃរដ្ឋម៉ាស្សាឈូសេត, ឬ
- ស្វែងរកតាមរយៈគេហទំព័រ: **www.mass.gov/jobquest**

2. ទូរស័ព្ទទៅកាន់ផ្នែក TOP ដើម្បីទទួលបាននូវទម្រង់បែបបទសម្រាប់ដាក់ពាក្យ: 617-626-5521
3. បំពេញផ្នែកដែលអ្នកត្រូវបំពេញនៃទម្រង់បែបបទពាក្យសុំ។ ស្នើរសុំកម្មវិធីបណ្តុះ បណ្តាលអ្នកអោយបំពេញផ្នែកដែលពួកគេត្រូវបំពេញ។
4. ផ្ញើពាក្យសុំដែលពេញលេញគ្រប់ជ្រុងជ្រោយរបស់អ្នកទៅកាន់កម្មវិធី TOP នៃផ្នែកជំនួយក្នុងភាពអត់ការងារធ្វើយ៉ាងហោចណាស់ **3 សប្តាហ៍ *មុន*** កម្មវិធីរបស់អ្នកចាប់ផ្តើម។

ប្រសិនបើអ្នកមិនបានលឺដំណឹងអ្វីពី TOP ក្នុងកំឡុ ងពេល3-4 សប្តាហ៍នៃការដាក់ពាក្យសុំចូលរួមទេនោះ , សូមទូរស័ព្ទទៅកាន់: **617-626-5521**.

## ត្រូវការជំនួយជ្រើសរើសកម្មវិធីបណ្តុះបណ្តាល?

ទៅកាន់មជ្ឈមណ្ឌលអាជីពការងារតែមួយដំណាក់ដែលបុគ្គលិកអាចជួយអ្នកស្វែងរកការបណ្តុះបណ្តាលដែលត្រឹមត្រូវ សក្តិសមសម្រាប់រូបអ្នក។

បុគ្គលិកមជ្ឈមណ្ឌលអាជីពការងារក៏អាច:

- វាយតម្លៃជំនាញការងាររបស់អ្នក,
- ផ្តល់ដល់អ្នកនូវបញ្ជីរាយនាមនៃកម្មវិធីបណ្តុះបណ្តាលដែលត្រូវបានអ នុម័តយល់ព្រម,
- ប្រាប់អ្នកថាតើអ្នកអាចបញ្ចប់ការបណ្តុះបណ្តាលបានមុនពេលអ្នកអស់អត្ថប្រយោជន៍នៃភាពអត់ការងារធ្វើរបស់អ្នកដែរឬទេ,
- ពន្យល់ជម្រើសរបស់អ្នកសម្រាប់ការបង់ថ្លៃការបណ្តុះបណ្តាល , និង
- ជួយអ្នកបំពេញពាក្យសុំចូលរួមក្នុងកម្មវិធី TOP។

## តើខ្ញុំអាចបាត់បង់អត្ថប្រយោជន៍ TOP របស់ខ្ញុំក្នុងកំឡុ ងនៃការបណ្តុះបណ្តាលដែរឬទេ?

មែនហើយ។ អ្នកអាចបាត់បង់អត្ថប្រយោជន៍អ្នកប្រសិនបើអ្នក:

- ឈប់សំណូមពរអំណះអំណាងពីភាពអត់ការងារធ្វើប្រចាំសប្តាហ៍របស់អ្នក,
- មិនរក្សាអោយបានទៅតាមលក្ខខណ្ឌតម្រូវទាមទាររបស់កម្មវិធីបណ្តុះបណ្តា ល,
- បញ្ឈប់កម្មវិធីបណ្តុះបណ្តាលមុនពេលអ្នកបញ្ចប់វាចប់ចុងចប់ដើម , ឬ
- ចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលលើសពីមួយក្នុងពេលតែម្តង (លុះត្រាតែកម្មវិធីផ្សេងដទៃទៀតគឺជាជំនាញមូលដ្ឋាន)។

ប្រសិនបើអ្នកកំពុងទទួលអត្ថប្រយោជន៍នៃភាពអត់ការងារធ្វើដែលពន្យារពេលដោយកម្មវិធី TOP នៅពេលការបណ្តុះបណ្តាលរបស់អ្នកចប់ នោះអត្ថប្រយោជន៍ TOP របស់អ្នកនឹងចប់នៅសប្តាហ៍ចុងក្រោយនៃកម្មវិធីបណ្តុះបណ្តាល។

***ចំណុចសំខាន់!*** ប្រសិនបើអ្នកកំពុងមានបញ្ហាជាមួយនឹងកម្មវិធីបណ្តុះបណ្តាល អ្នក, សូមទាក់ទងមកTOP ភ្លាមៗ។ សូមទូរស័ព្ទមកលេខ:**617-626-5521**។

## ប្រសិនបើកម្មវិធីបណ្តុះបណ្តាលការងាររបស់ខ្ញុំមានការសម្រាកវិស្សមកាល , តើអត្ថប្រយោជន៍ TOP របស់ខ្ញុំនឹងឈប់មានដែរឬទេ ?

**អត់ទេ**, ប្រសិនបើ:

- រយៈពេលវិស្សមកាលគឺ**តិចជាង 3 សប្តាហ៍**, ហើយ
- អ្នកទៅកាន់កម្មវិធីបណ្តុះបណ្តាលវិញភ្លាមៗបន្ទាប់ពីការសម្រាក។

ប្រសិនបើរយៈពេលវិស្សមកាល**លើសពី 3 សប្តាហ៍**, ហើយអ្នកបន្តស្វែងរកការងារដូចដែលតម្រូវនោះ, អ្នកប្រហែលនឹងអាចទទួលបាននូវអត្ថប្រយោជន៍យ៉ាងទៀងទាត់ប៉ុន្តែមិនមែនអត្ថប្រយោជន៍ភាពអត់ការងារដែលពន្យារបន្ថែមនោះឡើយ។

